ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ០០៥ សហវ

ភ្នំពេញ ,ថ្ងៃទី២៥ ខែ ធ្នូ ឆ្នាំ ២០០៣

# សារាចរណែនាំបន្ថែម

## ស្តីពី

## នីតិវិធី នៃការអនុវត្តន៍រជ្ជទេយ្យបុរេប្រទាន

**យោង** : - អនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ

- ប្រកាសលេខ : ០០៤ សហវ ប្រក / ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ
- ការវិវឌ្ឍន៍ នៃខឿនសេដ្ឋកិច្ចជាតិនាពេលបច្ចុប្បន្ន ។

ក្នុងគោលបំណងអោយការអនុវត្តន៍រជ្ជទេយ្យបុរេប្រទាន មានភាពរលូន ច្បាស់លាស់ និងបានឯកភាពគ្នាទូទាំងប្រទេស ទាំងថ្នាក់កណ្តាល ក៏ដូចជានៅថ្នាក់ខេត្ត-ក្រុង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការកែ សំរួលនូវនីតិវិធីចំណាយមួយចំនួន ដូចខាងក្រោម :

១- សំរេចជាគោលការណ៍ អោយគ្រប់ក្រសួង ស្ថាប័ន អាជ្ញាធរ ទាំងនៅថ្នាក់កណ្តាល និងថ្នាក់ខេត្ត-ក្រុង អនុវត្តចំណាយតាមនីតិវិធីរជ្ជទេយ្យបុរេប្រទាននូវ :
- ចំណាយតិចតួចអំពីសំភារៈ និងការថែទាំ
- ចំណាយសង្គ្រោះបន្ទាន់ និងពិសេស
- ចំណាយសំរាប់ធ្វើដំណើរ និង បេសសកម្មផ្សេងៗ ។

២- ចំនួនទឹកប្រាក់សំរាប់មួយគោលការណ៍ចំណាយ( មួយប័ណ្ណចំណាយ) ត្រូវបានកំណត់ត្រឹមចំនួន ១.០០០.០០០រ០០ ( មួយលានរៀល) ចុះ លើកលែងតែ ចំពោះរជ្ជទេយ្យបុរេប្រទានជំពូក១១សំរាប់ចំណាយពិសេសរបស់រាជរដ្ឋាភិបាលដែលមួយប័ណ្ណចំណាយអាចលើសពី ១.០០០.០០០រ០០ ( មួយលានរៀល ) ។

៣- រាល់ប័ណ្ណចំណាយត្រូវតែភ្ជាប់មកជាមួយនូវគោលការណ៍ចំណាយ និងវិក័យប័ត្រចំណាយមួយច្បាប់ (វិក័យប័ត្រដែលរជ្ជទេយ្យករបុរេប្រទានធ្វើការទូទាត់ ) ដោយមានការបញ្ជាក់ទទួលស្គាល់ពីប្រធានអង្គភាព ឬអ្នកដែលត្រូវបានផ្ទេរសិទ្ធិ ។

៤- ចំពោះប្រាក់បេសកកម្មក្នុងប្រទេស ដែលមានរបបកំណត់ច្បាស់លាស់ រជ្ជទេយ្យករបុរេប្រទានត្រូវធ្វើការ ទូទាត់

៤- ចំពោះប្រាក់បេសកកម្មក្នុងប្រទេស ដែលមានរបបកំណត់ច្បាស់លាស់ រដ្ឋទេយ្យករបុរេប្រទានត្រូវធ្វើការ ទូទាត់តាមការជាក់ស្តែង គឺក្នុងមួយប័ណ្ណចំណាយអាចស្មើ ឬលើសពី ១.០០០.០០០៛០០ ( មួយលានរៀល ) ។ ប៉ុន្តែចំពោះបេសកកម្មដែលមានថេរៈវេលាលើសពី ៦ ថ្ងៃ និងមានចំនួនមនុស្សច្រើនជាង ៥នាក់ ត្រូវផ្ទេរមកធ្វើការទូទាត់ត្រង់វិញ។ ការទូទាត់ប្រាក់បេសកកម្មនេះ ទោះបីអនុវត្តតាមនីតិវិធីរដ្ឋទេយ្យបុរេប្រទានក្តី ឬនីតិវិធីទូទាត់ត្រង់ក្តី ត្រូវតែភ្ជាប់មកជាមួយនូវ :

- លិខិតឧទ្ទេសនាម ឬ លិខិតបញ្ជាបេសកកម្ម
- ទិដ្ឋាការធ្វើដំណើរចំនួនមួយច្បាប់សំរាប់មន្ត្រី ១ រូប ដោយមានការចុះហត្ថលេខា និង ត្រាបញ្ជាក់ ពីថ្ងៃខែឆ្នាំ ចេញ ដំណើរ និង ទៅដល់ ពីស្ថាប័នមានសមត្ថកិច្ច ។

សរុបមួយបេសកកម្ម ចំណាយអាចមាន ១ ឬ ២ ឬ ៣ ប័ណ្ណចំណាយដោយត្រូវបំបែកទៅតាម វាក្យខ័ណ្ឌ :

- សោហ៊ុយបេសកកម្ម
- សោហ៊ុយ ដឹកជញ្ជូន
- សោហ៊ុយ ស្នាក់នៅ និង ហូបចុក ។

៥- ដោយឡែកចំពោះបេសកកម្មក្រៅប្រទេស អាចអនុវត្តតាមនីតិវិធីរដ្ឋទេយ្យបុរេប្រទានបាន ចំពោះតែបេសកកម្មទាំងឡាយណាដែលភាគីយើងទទួលបន្ទុក :

- ប្រាក់ហោប៉ៅ
- ប្រាក់បង់ពន្ធព្រលានយន្តហោះ
- ប្រាក់ទិញវត្ថុអនុស្សាវរីយ៍ ។

ចំពោះបេសកកម្មទាំងឡាយណា ដែលមានរួមទាំងសោហ៊ុយហូបចុក និងស្នាក់នៅ គឺត្រូវតែអនុវត្តតាមនីតិវិធីបុរេប្រទាន ឬ នីតិវិធីទូទាត់ត្រង់ ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសង្ឃឹមថា គ្រប់ក្រសួង ស្ថាប័ន អាជ្ញាធរ ទាំងថ្នាក់កណ្តាល និងថ្នាក់ខេត្ត-ក្រុង នឹងជួយសហការគោរពអនុវត្តតាមសេចក្តីណែនាំនេះអោយមានប្រសិទ្ធភាពល្អប្រសើរ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

**<u>ចំលងជូន</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងស្ថាប័ន ថ្នាក់កណ្តាល
- ខេត្ត-ក្រុង
- ឯកសារ-កាលប្បវត្តិ